ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ១៥៤/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

កម្ពុជាធ្វើបច្ចុប្បន្នភាពដំនអង្គទូតអំពីវឌ្ឍនភាព នៃការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងទិសដៅអនាគត

នៅរសៀលថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៦ **ឯកឧត្តម ឆៃ ស៊ីណាវិទ្ធ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (CCOS) បានធ្វើបទបង្ហាញជូនសមាជិកអង្គទូត និងតំណាងអង្គការអន្តរជាតិនានានៅរាជធានីភ្នំពេញ សរុបចំនួន៤៦រូប អំពីវឌ្ឍនភាព និងទិសដៅអនាគតរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ បទបង្ហាញនេះត្រូវបានសម្របសម្រួលដោយ **លោកជំទាវ អ៊ាត សោភា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងមានការចូលរួមតាមប្រព័ន្ធវីដេអូពីតំណាងបេសកកម្មការទូតកម្ពុជានៅក្រៅប្រទេសផងដែរ។

លោកជំទាវ អ៊ាត សោភា បានធ្វើការកត់សម្គាល់ និងថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ដែលបានអញ្ជើញចូលរួមស្តាប់បទបង្ហាញលើកទី៤នេះ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា បន្ទាប់ពីបទបង្ហាញលើកទី៣ ដែលបានប្រព្រឹត្តទៅកាលពីខែសីហា ឆ្នាំ២០២៦។ **លោកជំទាវ**បានរំលឹកអំពីភាពជោគជ័យរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅរាជធានីភ្នំពេញ ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៦ (ICCOS 2026) ក្រោមមូលបទ «រួមគ្នាឆ្ពោះទៅកាត់ផ្តាច់ខ្សែច្រវាក់ និងបញ្ចប់ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា» ដែលមានគណៈប្រតិភូចូលរួមប្រមាណ៦០០រូប រួមមានអ្នកតាក់តែងគោលនយោបាយ ភ្នាក់ងារអនុវត្តច្បាប់ និយ័តករហិរញ្ញវត្ថុ និងអ្នកជំនាញបច្ចេកវិទ្យា មកពីប្រទេសចំនួន២៨ និងអង្គការអន្តរជាតិចំនួន៧។ កម្ពុជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួម និងសហអ្នករៀបចំសន្និសីទទាំងអស់ដោយអង្គប្រជុំបានអនុម័តនូវការប្តេជ្ញាចិត្តចំនួន១១ចំណុច ដែលបានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងភ្នំពេញ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការលុបបំបាត់ហេដ្ឋារចនាសម្ព័ន្ធឆបោក រឹបអូសទ្រព្យសម្បត្តិខុសច្បាប់ និងកិច្ចការពារជនរងគ្រោះ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ឆៃ ស៊ីណាវិទ្ធ បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តផ្នែកមនុស្សធម៌ដ៏សំខាន់ចំនួនពីរនៃការប្តេជ្ញាចិត្តខាងលើ ខណៈដែលស្ថាប័នអនុវត្តច្បាប់កម្ពុជាកំពុងបន្តកិច្ចខិតខំប្រឹងប្រែង រាប់ម្ល៉ឺនាំជនល្មើសមកផ្តន្ទាទោសតាមច្បាប់ ជាមួយនឹងការផ្តល់ការគាំទ្រនិងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

មនុស្ស និងបុគ្គលដែលងាយរងគ្រោះ ព្រមទាំងការអនុវត្តគោលការណ៍មិនដាក់ទោសទណ្ឌចំពោះអ្នកដែលបានធ្លាក់ខ្លួនជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឬត្រូវបានបង្ខំឱ្យប្រព្រឹត្តសកម្មភាពល្មើសច្បាប់។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានសង្កត់ធ្ងន់បន្ថែមថា កិច្ចខិតខំប្រឹងប្រែងរួម និងកិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាកត្តាចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ ឯកឧត្តមបានគូសបញ្ជាក់ពីវឌ្ឍនភាពដ៏ធំធេង ដែលសម្រេចបាន តាមរយៈប្រតិបត្តិការបង្ក្រាប និងយុទ្ធនាការអនុវត្តច្បាប់នៅទូទាំងប្រទេស ដោយមានការគាំទ្រ និងការចែករំលែកព័ត៌មានពីដៃគូជាច្រើន។ រហូតមកដល់ពេលនេះ អាជ្ញាធរកម្ពុជាបានស៊ើបអង្កេតទីតាំងសង្ស័យចំនួន៩៧២ទីតាំង បង្កកប្រាក់ក្នុងគណនីធនាគារចំនួនជាង៣០០លានដុល្លារអាម៉េរិក និងទ្រព្យសម្បត្តិចលនវត្ថុ និងអចលនវត្ថុមានតម្លៃជិតមួយប៊ីលានដុល្លារអាម៉េរិក ព្រមទាំងបានបណ្តេញចេញជនបរទេសជាង២៣.០០០នាក់ ដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ឆៃ ស៊ីណាវិទ្ធ បានកត់សម្គាល់ថា ទោះបីជាទីតាំងប្រតិបត្តិការឆបោកទ្រង់ទ្រាយធំទាំងអស់ ត្រូវបានលុបបំបាត់នៅកម្ពុជាក៏ដោយ ក៏បណ្តាញឧក្រិដ្ឋជននៅតែមាន និងបន្តសម្របខ្លួន ដោយប្តូរទៅធ្វើប្រតិបត្តិការជាទ្រង់ទ្រាយតូចៗ និងបែកខ្ញែកនៅតាមបន្ទប់ជួល សណ្ឋាគារ ហាងការ៉ាអូខេ និងតំបន់ជាច់ស្រយាលនានា។ ពាក់ព័ន្ធនឹងការវិវឌ្ឍថ្មីៗនៃការអនុវត្តច្បាប់ ឯកឧត្តមបានបញ្ជាក់ថា អាជ្ញាធរកំពុងពិនិត្យយ៉ាងហ្មត់ចត់លើកស្តុតាងដែលមាន ដើម្បីស៊ើបអង្កេតរាល់ការសង្ស័យអំពីការជាប់ពាក់ព័ន្ធ ឬការឃុបឃិតរបស់ក្រុមហ៊ុនសន្តិសុខឯកជន ឬមន្ត្រីនានា ក្នុងសកម្មភាពខុសច្បាប់ទាំងនេះ។ ឯកឧត្តមក៏បានបញ្ជាក់ជាថ្មីថា រាជរដ្ឋាភិបាលនឹងមិនមើលរំលងក្រុមហ៊ុន ឬបុគ្គលណាមួយដែលត្រូវបានសង្ស័យថា បានផ្តល់ជម្រក ការការពារ ឬសម្រួលដល់បណ្តាញ ឬប្រតិបត្តិការឆបោក នោះឡើយ។

ទៅអនាគត **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ ដើម្បីការពារជនរងគ្រោះ និងទប់ស្កាត់ការកើតឡើងវិញ នៃបណ្តាញឆបោកតាមប្រព័ន្ធបច្ចេកវិទ្យានេះ។ ឯកឧត្តម បានស្នើឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្តបន្ទាប់ និងមានការជឿទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសការចែករំលែកព័ត៌មានជាក់ស្តែង កិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តច្បាប់ និងការជួយកសាងសមត្ថភាពទៅវិញទៅមក។ ជាចុងក្រោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ជាថ្មីអំពីការត្រៀមខ្លួនជាស្រេចរបស់កម្ពុជាក្នុងការចែករំលែកបទពិសោធន៍ប្រតិបត្តិការ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអន្តរជាតិ ដើម្បីលុបបំបាត់បណ្តាញឧក្រិដ្ឋកម្មឆ្លងដែន ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។

កិច្ចធ្វើបទបង្ហាញនេះត្រូវបានបិទបញ្ចប់ដោយមានវគ្គសំណួរ និងចម្លើយ។

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៦